**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :............០២៥/១៦............ក.ប/ស.ណ.ន

# សេចក្តីណែនាំ

## ស្តីពី

## ការចុះបេសកកម្ម

ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ តម្លាភាព និងគណនេយ្យភាព នៃការចុះបំពេញបេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធី នៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រសួងសូមធ្វើការណែនាំដល់ប្រធានអង្គភាព និងមន្ត្រីរាជការក្រោមឱវាទ ពេលចុះបំពេញបេសកកម្មត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១. ត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃវិជ្ជាជីវៈ និងគុណតម្លៃបុគ្គល ក្នុងការបំពេញមុខងារសាធារណៈ។ ការចុះបំពេញបេសកកម្មមិនត្រូវលើសពី១០ថ្ងៃ ក្នុងមួយខែ។

២. មិនត្រូវ៖

- យកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែង
- ការក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្ម ដែលខ្លួនពុំមានសិទ្ធិទទួលតាមបទប្បញ្ញត្តិជាធរមាន
- ការបង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- ការបង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះបេសកកម្ម ដែលខុសពីបេសកកម្មដែលបានអនុវត្តជាក់ស្តែង
- ការបង្កើតបេសកកម្មដោយក្លែងបន្លំ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ការទទួលបានប្រាក់បេសកកម្មតែមិនបានផ្តល់ជូនសាមីមន្ត្រីរាជការសាធារណៈ ដែលត្រូវបំពេញបេសកកម្ម
- ការរារាំង ឬការព្យាយាមរារាំង ដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តប្រាក់បេសកកម្ម។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា **ឯកឧត្តម លោកជំទាវ ជាប្រធានអង្គភាព និងមន្ត្រីរាជការគ្រប់រូប គ្រប់លំដាប់ថ្នាក់** ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- គ្រប់ថ្នាក់ដឹកនាំក្រសួង
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ-កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៥*